**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

ក្រសួងសុខាភិបាល

លេខ ០៦៦ ស.ឋ

ថ្ងៃពុធ ៨ កើត ខែចេត្រ ឆ្នាំជូត ទោស័ក ព.ស.២៥៦៣

រាជធានីភ្នំពេញ, ថ្ងៃទី ១៥ ខែ មេសា ឆ្នាំ២០២០.

**រដ្ឋមន្ត្រីក្រសួងសុខាភិបាល**

**គោរពជូន**

**ឯកឧត្តមរដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

**កម្មវត្ថុ៖** សំណើសុំចាត់វិធានការចត្តាឡីស័ក រយៈពេល ១៤ថ្ងៃ លើកម្មករ កម្មការិនី ដែលនឹងវិលត្រឡប់ចូលបម្រើការងារវិញបន្ទាប់ពីពិធីបុណ្យចូលឆ្នាំខ្មែរប្រពៃណីជាតិ ។

**យោង៖**
- ចំណារឯកភាពដ៏ខ្ពង់ខ្ពស់របស់ **សម្តេចតេជោនាយករដ្ឋមន្ត្រី** ចុះថ្ងៃទី១៥ ខែមេសា ឆ្នាំ២០២០
- សេចក្តីណែនាំ ចុះថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២០ របស់ក្រសួងសុខាភិបាល ស្តីពីនីតិវិធីដាក់ខ្លួនឱ្យនៅដាច់ដោយឡែកក្នុងរយៈពេល១៤ថ្ងៃ ដើម្បីបង្ការនិងទប់ស្កាត់ជំងឺកូវីដ១៩ នៅតាមផ្ទះជាលក្ខណៈបុគ្គល។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាបជូន **ឯកឧត្តមរដ្ឋមន្ត្រី** មេត្តាជ្រាបថា ស្ថានភាពជំងឺកូវីដ១៩ ស្ថិតនៅក្នុងដំណាក់កាលដែលយើងត្រូវតែមានការប្រុងប្រយ័ត្នខ្ពស់បំផុត ដើម្បីកុំឲ្យមានការចម្លងរាតត្បាតចូលក្នុងសហគមន៍ ជាពិសេសការធ្វើដំណើរចល័តរបស់បុគ្គលពីកន្លែងមួយទៅកន្លែងមួយ ដែលមិនបានគោរពតាមបទបញ្ជារបស់ **សម្តេចតេជោនាយករដ្ឋមន្ត្រី** នាឱកាសបុណ្យចូលឆ្នាំប្រពៃណីជាតិខ្មែរ ដែលមានការសម្រុកចេញទៅស្រុកកំណើតកន្លងមកនេះ។ ដើម្បីបង្ការហានិភ័យនៃការចម្លងវីរុសកូវីដ១៩ ចំពោះកម្មករ កម្មការិនី ដែលនឹងត្រូវវិលត្រឡប់មកកន្លែងធ្វើការនៅតាមរោងចក្រ សហគ្រាសរបស់ពួកគាត់វិញនោះ ក្រសួងសុខាភិបាល សូមស្នើក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សហការចាត់វិធានការលើបុគ្គលទាំងនោះ ដោយត្រូវតែដាក់ខ្លួនឲ្យនៅដាច់ដោយឡែក (ចត្តាឡីស័ក) នៅកន្លែងស្នាក់នៅរបស់បុគ្គលនោះ ក្នុងរយៈពេលចំនួន ១៤ថ្ងៃ ជាចាំបាច់ ព្រមទាំងមានការតាមដានក្នុងការអនុវត្តវិធានការចត្តាឡីស័ក និងត្រួតពិនិត្យតាមដានសុខភាព ពីក្រុមគ្រូពេទ្យនៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ហើយប្រសិនបើមានបុគ្គលណាម្នាក់មានបញ្ហាសុខភាព ដែលពាក់ព័ន្ធទៅនឹងជំងឺកូវីដ១៩ ក្រុមគ្រូពេទ្យនៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ត្រូវតែទំនាក់ទំនងមកក្រសួងសុខាភិបាល តាមរយៈលេខ ១១៥ ឬទូរស័ព្ទលេខ ០១២ ៨២៥ ៤២៤ ឬ ០១២ ៩៥៨ ១៧៩ ដើម្បីជួយផ្តល់អន្តរាគមន៍ក្នុងការពិនិត្យ និងធ្វើរោគវិនិច្ឆ័យបុគ្គលនោះបានទាន់ពេលវេលា។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូម **ឯកឧត្តមរដ្ឋមន្ត្រី** មេត្តាសម្រេចតាមការគួរ។

សូម **ឯកឧត្តមរដ្ឋមន្ត្រី** មេត្តាទទួលនូវការគោរពរាប់អានពីខ្ញុំ។

**ម៉ម ប៊ុនហេង**